## យុវវ័យ

# ត្រូវបានភ្ជាប់ជាមួយក្រុមគ្រួសាររបស់ខ្ញុំអស់កល្បជានិច្ច

ដោយ ឡូរ៉ា ប៊ីតចុន

ពេលខ្ញុំត្រូវបានយកមកចិញ្ចឹមនៅអាយុបីឆ្នាំ ម្ដាយបង្កើតរបស់ខ្ញុំបានអនុញ្ញាតឲ្យការចិញ្ចឹមនោះសម្រេចបាន លើកលែងតែឪពុកម្ដាយខ្ញុំយល់ព្រមឲ្យខ្ញុំទទួលពិធីបរិសុទ្ធទាំងឡាយនៃសាសនាចក្របន្ទាប់ពីខ្ញុំចូលដល់អាយុ ១២ ឆ្នាំ ហើយប៉ុណ្ណោះ ។ គាត់បានគិតថា ខ្ញុំត្រូវតែមានអាយុធំល្មមដើម្បីធ្វើការសម្រេចចិត្តសម្រាប់ខ្លួនឯងសិន ប៉ុន្តែ វាពិបាកនឹងចាំណាស់ ។

មែនហើយ វាពិបាកដែលឃើញមិត្តភក្តិខ្ញុំជាច្រើនទទួលបុណ្យជ្រមុជទឹកនៅពេលពួកគេមានអាយុប្រាំបីឆ្នាំ ប៉ុន្តែអ្វីដែលពិបាកជាងនោះទៅទៀត គឺការដឹងថា ខ្ញុំពុំអាចផ្សារភ្ជាប់ជាមួយឪពុកម្ដាយចិញ្ចឹម និង បងៗចិញ្ចឹមប្រាំនាក់របស់ខ្ញុំបាន ទាល់តែខ្ញុំមានអាយុ ១២ ឆ្នាំ ។ ខ្ញុំខ្លាចថា បើមានអ្វីកើតឡើងចំពោះខ្ញុំ នោះខ្ញុំនឹងពុំអាចផ្សារភ្ជាប់ជាមួយនឹងពួកគាត់បាន ។

កាលដែលខ្ញុំជិតចូលដល់អាយុ ១២ ឆ្នាំ នោះយើងបានចាប់ផ្ដើមដាក់ផែនការសម្រាប់បុណ្យជ្រមុជទឹក និង ការផ្សារភ្ជាប់ជាមួយក្រុមគ្រួសារខ្ញុំ ។ ឪពុកម្ដាយខ្ញុំបានអនុញ្ញាតឲ្យខ្ញុំជ្រើសរើសព្រះវិហារបរិសុទ្ធដែលយើងនឹងទៅផ្សារភ្ជាប់ ។ ខ្ញុំតែងតែគិតថា ព្រះវិហារបរិសុទ្ធ សាន់ឌីអាហ្គូ កាលីហ្វញ៉ា ជាព្រះវិហារបរិសុទ្ធដ៏ស្រស់ស្អាតបំផុត ដូច្នេះក្រុមគ្រួសារខ្ញុំទាំងមូលបានយល់ស្របបើកឡានទៅកាលីហ្វញ៉ា សម្រាប់ការផ្សារភ្ជាប់ ។

ខ្ញុំពុំអាចរង់ចាំដើម្បីក្លាយជាក្រុមគ្រួសារដ៏អស់កល្បជានិច្ចជាមួយនឹងឪពុកម្ដាយ និង បងៗខ្ញុំនោះទេ ។ អំឡុងពេលនៃការផ្សារភ្ជាប់របស់ខ្ញុំ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណយ៉ាងខ្លាំង ដែលពិបាកនឹងពន្យល់ ។ ឥឡូវនេះ ដោយខ្ញុំបានផ្សារភ្ជាប់ជាមួយនឹងក្រុមគ្រួសារខ្ញុំនៅទីបំផុត នោះអារម្មណ៍ព្រួយបារម្ភដែលខ្ញុំបានមាន ត្រូវបានជំនួសដោយការលួងលោម និង អារម្មណ៍សុខសាន្ត ដោយដឹងថា ឥឡូវនេះ ខ្ញុំត្រូវបានភ្ជាប់នឹងពួកគាត់អស់កល្បជានិច្ច ។

*អ្នកនិពន្ធរស់នៅ រដ្ឋ យូថាហ៍ ស.រ.អា ។*



## កុមារ





# ការសំឡឹងទៅឯព្រះវិហារបរិសុទ្ធ

ប្រធាន អាវរិង ពន្យល់ថា ដោយសារអំណាចបព្វជិតភាព នោះយើងមានឱកាសដើម្បីទៅព្រះវិហារបរិសុទ្ធដើម្បីផ្សារភ្ជាប់ជាមួយនឹងក្រុមគ្រួសាររបស់យើងសម្រាប់ភាពអស់កល្បជានិច្ច ។ សូមគូរ ឬ ស្វែងរករូបភាពនៃព្រះវិហារបរិសុទ្ធដែលអ្នកចូលចិត្ត ហើយដាក់វានៅកន្លែងដែលអ្នកអាចមើលឃើញជារៀងរាល់ថ្ងៃ ។ សូមធ្វើបញ្ជីមួយអំពីរបៀបដែលអ្នកនឹងរៀបចំខ្លួនដើម្បីទៅកាន់ព្រះវិហារបរិសុទ្ធនៅថ្ងៃណាមួយ ។

រូបថតព្រះវិហារបរិសុទ្ធ សាន់ឌីអាហ្គូ កាលីហ្វញ៉ា